# ក

# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៨-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២៧១ ស្ដីពីការតែងតាំងទីប្រឹក្សា និងជំនួយការសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ ចំនួន ១៨ រូប ៨៧១៨

២៨-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២៧៤ ស្ដីពីការធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី និង ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ចំនួន ១៦ រូប ៨៧២០

២៨-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២៧៥ ស្ដីពីការតែងតាំងជំនួយការឯកឧត្តម **ម៉េង សំរិទ្ធិ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ចំនួន ០២ រូប ៨៧២២

២៨-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២៧៦ ស្ដីពីការតែងតាំងឯកឧត្តម **នៅ កាស៊ី** ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ៨៧២៣

២៨-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២៧៧ ស្ដីពីការតែងតាំងឯកឧត្តម **ស៊ុយ សារ៉េត** ជាទីប្រឹក្សាក្រសួងអប់រំយុវជន និងកីឡា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៨៧២៤

២៨-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២៧៨ ស្ដីពីការតែងតាំងឯកឧត្តម **ហ៊ី ហួរ** ជាអនុរដ្ឋលេខាធិការក្រសួងផែនការ ៨៧២៥

២៨-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២៧៩ ស្ដីពីការតែងតាំងទីប្រឹក្សាអមរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ចំនួន ០២ រូប ៨៧២៦

០១-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៨១ ស្ដីពីការផ្ទេរមុខងារ និងតម្លើងឋានៈជូនឯកឧត្តម និងលោកជំទាវ ជាទីប្រឹក្សា និងជំនួយការសម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ចំនួន ១១ រូប ៨៧២៧

០១-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៨២ ស្ដីពីការតម្លើងថ្នាក់ឯកឧត្តម **ហង់ ជួនណារ៉ុន** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៨៧២៨

០១-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៨៣ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **នាយ សុវណ្ណ** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៨៧៣០

០១-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៨៤ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក ជូនលោកឧត្តមសេនីយ៍ទោ **ពេជ្រ ជីវ័ន្ត** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៨៧៣១

០១-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៨៥ ស្តីពីការតែងតាំងឯកឧត្តម **ឌិន ទីរះ** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៨៧៣២

០១-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៨៦ ស្តីពីការតែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ៨៧៣៣

០២-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៩០ ស្តីពីការតែងតាំងឯកឧត្តម **ឯក ផាវ** ជាទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៨៧៣៤

០២-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៩១ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **សោ ពន្លក** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៨៧៣៥

០២-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៩២ ស្តីពីការតែងតាំងឯកឧត្តម **សម សារិន** ជាទីប្រឹក្សា អមក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៨៧៣៦

០២-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៩៣ ស្តីពីការតែងតាំងឯកឧត្តម **លី ផល្លា** ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ មានឋានៈស្មើ រដ្ឋលេខាធិការ ៨៧៣៧

០៣-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១២៩៥ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុំ វណ្ណា** ជានាយករងខុទ្ទកាល័យ និងជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី ៤ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៨៧៣៨


## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


០៣-១២-២០០៨ -អនុក្រឹត្យលេខ ២០២ អនក្រ.បក ស្តីពីការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត និងផ្លូវការ ៨៧៣៩

០៤-១២-២០០៨ -អនុក្រឹត្យលេខ ២០៣ អនក្រ.បក ស្តីពីការបិទស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋប៉ូឡូញ ៨៧៤៥

០១-១២-២០០៨ -អនុក្រឹត្យលេខ ១២៦០ អនក្រ.បក ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ៨៧៤៦
០១-១២-២០០៨ -អនុក្រឹត្យលេខ ១២៦១ អនក្រ.បក ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៧៤៧
០១-១២-២០០៨ -អនុក្រឹត្យលេខ ១២៦២ អនក្រ.បក ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៧៤៨
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៦៣ អនក្រ.បក ស្តីពីការតែងតាំងមុខងារ នាយទាហាន ៨៧៤៩
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៦៤ អនក្រ.បក ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៨៧៥០
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៦៥ អនក្រ.បក ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨៧៥៤
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៦៦ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៥៥
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៦៧ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៥៦
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៦៨ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៥៧
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៦៩ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៥៩
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៧០ អនក្រ.បក ស្តីពីការជូនមេដាយសហមេត្រី ៨៧៦០
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៧១ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៦២
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៧២ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៦៣
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៧៣ អនក្រ.បក ស្តីពីការជូនមេដាយការងារ ៨៧៦៤
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៧៤ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៦៥
០២-១២-២០០៨ -អនុក្រឹត្យលេខ ១២៧៥ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៧៦៦

## ២_សារាចរណែនាំ

០៥-១២-២០០៨ -សារាចរណែនាំលេខ ០៦ សរណន ស្តីពីការធ្វើអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លតម៉ាស៊ីន) ៨៧៦៧

## III_ការងារបណ្តាក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៦-១១-២០០៨ -ប្រកាសលេខ ១៣៨៤ សហវ.ប្រក ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការទីស្នាក់ការគយ និងរដ្ឋាករប្រចាំសន្និធិគយបណ្តោះអាសន្ន បុក សេង ភីភី អេស អ៊ី ហ្សេត ដ្រាយ ផត (ទីស្នាក់ការគយ និងរដ្ឋាករ ផែស្ងួត បុក សេង) ៨៧៦៩

## ២_ធនាគារជាតិ នៃ កម្ពុជា

២៥-១១-២០០៨ -ប្រកាសលេខធ៧.០៨.២១១ ប្រក ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ៨៧៧១

២៥-១១-២០០៨ -ប្រកាសលេខ ធ៧.០៨.២១២ ប្រក ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសំរាប់បុគ្គល ដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណ ៨៧៩២

## ៣-ឯកសារក្រសួងពាណិជ្ជកម្ម

១៥-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣១៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល អិម ធី ធី** ៨៨១០

១៥-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣១៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមថៃទីវ៉ាណាន អេឡិកត្រិក** ៨៨១២

១៥-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣១៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខនសីទេសិន វើតទេនឈ័រ ធួរ** ៨៨១៤

១៥-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣១៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាវិត ស្តារស៊ីធី ហូថេល** ៨៨១៦

១៦-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣១៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដុំ-លីន អុិនធើណេសិនណល ខមភេនី** ៨៨១៨

១៦-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣១៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន ហ្វីស ឌីវេឡុបមេន** ៨៨២០

១៦-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣២០០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ព្យូឈ័រ ស៊ីធី** ៨៨២២

# ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤ ។

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**<u>មាត្រា១</u>** : ត្រូវបានតែងតាំង ជាទីប្រឹក្សា និងជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ :

**ក-ទីប្រឹក្សា :**

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **រ័ត្ន សុខន** | មានឋានៈស្មើ | **រដ្ឋមន្ត្រី** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២- ឯកឧត្តម | **ស៊ីន យឹម** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | |
| ៣-ឯកឧត្តម | **សុខ គង់** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤-ឯកឧត្តម | **អ៊ុក សារាវុធ** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥-ឯកឧត្តម | **ហួត ហាក់** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៦-ឯកឧត្តម | **នួន ប៉ោលីន** | មានឋានៈស្មើ | **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៧-ឯកឧត្តម | **ស្វាយ សុធី** | មានឋានៈស្មើ | **អនុរដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៨-ឯកឧត្តម | **សេង ធុន្ថា** | មានឋានៈស្មើ | **អនុរដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៩-ឯកឧត្តម | **ប៊ុក វណ្ណធីរ** | មានឋានៈស្មើ | **អនុរដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

១០-ឯកឧត្តម **ស៊ុយ ឆៃលាង** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

១១-ឯកឧត្តម **ម៉ែន ប៊ូនពីច** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

១២-ឯកឧត្តម **នូ ឈន់** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

១៣-ឯកឧត្តម **សោម ឫទ្ធី** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

១៤-ឯកឧត្តម **ចន្ទ្រ អែមសំអាន** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

១៥-ឯកឧត្តម **ម៉ែន សុក្រ** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

១៦-ឯកឧត្តម **ជែត សុចរិត** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

**ខ-ជំនួយការៈ**

១-ឯកឧត្តម **ស៊ីម សារិន** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម **ចន្ថា ជែត** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

**<u>មាត្រា២</u>** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**<u>មាត្រា៣</u>** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស/រកត.០៩១១.១២៩០*

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨*

លេខ:៦៦៩៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១២៧៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុង **ឋានន្តរស័ក្តិ ឧត្តមមន្ត្រី** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ នូវមន្ត្រីរាជការ ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១ - ឯកឧត្តម **ជិន សារិន** | ឋានន្តរស័ក្តិ ឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ២ - ឯកឧត្តម **ជា សុផន** | ឋានន្តរស័ក្តិ ឧត្តមមន្ត្រី | ថ្នាក់លេខ ៥ ។ |

**មាត្រា ២ :** ត្រូវបានធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុង **ឋានន្តរស័ក្តិ អនុមន្ត្រី** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ នូវមន្ត្រីរាជការ ចំនួន ១៤ រូប ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១ -លោក **ស ធារិទ្ធ** | ឋានន្តរស័ក្តិ **អនុមន្ត្រី** | ថ្នាក់លេខ ៧ |
| ២ -លោក **មុត មុន** | ឋានន្តរស័ក្តិ **អនុមន្ត្រី** | ថ្នាក់លេខ ៧ |
| ៣-លោក **សួន សំណាង** | ឋានន្តរស័ក្តិ **អនុមន្ត្រី** | ថ្នាក់លេខ ៩ |
| ៤ -លោក **ញឹម ចន្ទ្ររិន** | ឋានន្តរស័ក្តិ **អនុមន្ត្រី** | ថ្នាក់លេខ ៩ |
| ៥ -លោកស្រី **ឈន់ នេងលាង** | ឋានន្តរស័ក្តិ **អនុមន្ត្រី** | ថ្នាក់លេខ ១០ |
| ៦ -លោក **វឿន ទ៉េង** | ឋានន្តរស័ក្តិ **អនុមន្ត្រី** | ថ្នាក់លេខ ១០ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៧ -លោក **ឆែល ស៊ីថា** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១០

៨ -លោក **សេខ គន្ធ** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១១

៩ -លោក **ហោ ចិនវិរយុទ្ធ** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១២

១០ -លោក **សុខ ចំរើន** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៣

១១ -លោក **ម៉ុច គីមហួត** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៤

១២ -លោក **ហួន ចំនួនតេនា** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៤

១៣ -លោក **រស់ ផារិទ្ធ** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៤

១៤ -លោក **ឡុខ សត្យា** ឋានន្តរស័ក្តិ **អនុមន្ត្រី** ថ្នាក់លេខ ១៤ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យ បានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត/១១០៨/១២៨៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨*

លេខ:១៥០០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃ៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២៧៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងជំនួយការឯកឧត្តម **វ៉េង សិរីវុឌ្ឍ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដូចមានរាយនាមខាងក្រោម :

១_ឯកឧត្តម **សូ សាមុត** មានឋានៈស្មើ **អគ្គនាយក**

២_ឯកឧត្តម **ពូន ចន្ធនី** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រោ.០៩១១.១២៩៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨*

លេខៈ ១១៩៥ ច.ល

[illegible]ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៨

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម នៅ ការស៊ី ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ: ១១៩៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨

**ស៊ុន ចិន្តា**

ជ.រ.ល. ០៧១១. ១២៩៥

**សួន ជិនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ស៊ុយ សារ៉េត** ជាទីប្រឹក្សាក្រសួងអប់រំយុវជន និងកីឡា មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ការ.០៩១១.១២៩៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខៈ ១១៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៨
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ម៉ី ម្សារ ជាអនុរដ្ឋលេខាធិការក្រសួងផែនការ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧៧.០៩១១.១២៩៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខ:១១៩៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២៧៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងទីប្រឹក្សាអមរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ដូចមានរាយនាមខាងក្រោម :

១ - ឯកឧត្តម សុខ ម៉ាឡឿង មានឋានៈស្មើ រដ្ឋលេខាធិការ
២ - ឯកឧត្តម ឆន់ ចន មានឋានៈស្មើ អនុរដ្ឋលេខាធិការ

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ល.០៩១១.១២៩៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខ:១១៩៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេង

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១២៩១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** - ផ្ទេរមុខងារ និងតម្លើងឋានៈជូន :

- លោកជំទាវ **សោម សោភ័ណ្ឌី** ពីជំនួយការមកជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋមន្ត្រី

- តម្លើងឋានៈ ជូនទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឡុច សារ៉េត** | មានឋានៈស្មើ | រដ្ឋមន្ត្រី |
| ២-ឯកឧត្តម | **ជីវ សុខហាត់** | មានឋានៈស្មើ | រដ្ឋមន្ត្រី |
| ៣-ឯកឧត្តម | **ចិញ្ច ហ៊្សុរ** | មានឋានៈស្មើ | រដ្ឋមន្ត្រី |
| ៤-ឯកឧត្តម | **សុខ ហ៊ាង** | មានឋានៈស្មើ | រដ្ឋលេខាធិការ |
| ៥-ឯកឧត្តម | **ហាត់ ម៉ៅ** | មានឋានៈស្មើ | រដ្ឋលេខាធិការ |
| ៦-ឯកឧត្តម | **សយ ស៊ីផាន់ណា** | មានឋានៈស្មើ | រដ្ឋលេខាធិការ |

- តម្លើងឋានៈ ជូនជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ហ៊ាង សេរីវុទ្ធ** | មានឋានៈស្មើ | រដ្ឋលេខាធិការ |
| ២-ឯកឧត្តម | **តែប ស្រ៊ុន** | មានឋានៈស្មើ | អនុរដ្ឋលេខាធិការ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- តែងតាំង :

១-ឯកឧត្តម គីម សាឡូន ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

២-ឯកឧត្តម សោ ឌីរ៉ូ ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អគ្គនាយក

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស/រកត/១២០៨/១៣០០*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨*

លេខ: ១២០៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤៩២

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងថ្នាក់ឯកឧត្តម **មាន់ ជួនណារ៉ុន** ពីឧត្តមមន្ត្រី **ថ្នាក់លេខ ៤** ទៅឧត្តមមន្ត្រី **ថ្នាក់លេខ ២** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩១៤.១៣០១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨*

លេខ: ១ ២០២៨.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៨
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ចាន់ថុល**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១២៩៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **ឆាយ សុខណ្ណ** អត្តលេខ ០៧៤៧ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.០៩១២.១៣០២

លេខៈ ១២០៩ ច.ល

**ដើម្បីចម្លងចែក**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨*

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១២៩៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកឧត្តមសេនីយ៍ទោ **ពេជ្រ ជីវ័ន្ត** អត្តលេខ ០១០២ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣ល.០៩១២.១៣០៣

លេខៈ ១២១១ ច.ល

ដើម្បីចម្លងចែក

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨*

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៨

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១២៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ឌិន ទីរៈ** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៤៧.០៩១២.១៣០៤

ធ្វើទៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨

លេខៈ ៦២០១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១២៩៦

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដូចមាននាមខាងក្រោម ÷

| | | |
|---|---|---|
| ១-ឯកឧត្តម **ពុត ចន្ថារិទ្ធិ** | មានឋានៈស្មើ | រដ្ឋលេខាធិការ |
| ២-ឯកឧត្តម **ញ៉ឹក សារឿន** | មានឋានៈស្មើ | អនុរដ្ឋលេខាធិការ |
| ៣-ឯកឧត្តម **ញ៉ី ម្សួង** | មានឋានៈស្មើ | អនុរដ្ឋលេខាធិការ |

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

នរោត្តម សីហមុនី

៣រល.០៩១២.១៣០៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨*

លេខៈ ១២០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនគេង

នស/រកត/១២០៨/១៤៩០

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/ ០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ឯក ផា** ជាទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩១២.១៣០៥

លេខ: ១៧០៤ច.ល

**ដើម្បីចម្លងចែក**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៨*

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ប៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **តោ ពន្លក អត្តលេខ ០២០៩៤** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួល បន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣៧.០៩១២.១៣១០*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨*

លេខ: ១២១០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១២៩២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម សម សារិន ជាទីប្រឹក្សាក្រសួងពត៌មាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧ល.០៩១២.១៣១១

លេខ:១២០៧/ច.ល
ដើម្បីចម្លងចែក

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨*

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤៩៣

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានតួមិជាតិសាសនា រតនត្ដិយា ខេមរដ្ឋារស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្ដម **លី ផល្លា** ជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ: ១២០៦ ច.ល

ជូនដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៨

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ពរល.០៩១៤.១៣១៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១២៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំង **ឯកឧត្តម អ៊ុំ ខណ្ណា** ជានាយករងខុទ្ទកាល័យ និងជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣១ល.០៩១២.១៣១៤

លេខ: ១២០៥ ច.ល

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៨

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចិន្តា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត និងផ្លូវការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត និងផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។

### ជំពូកទី ២

### អំពីលិខិតឆ្លងដែនការទូត

**មាត្រា ២.-**

លិខិតឆ្លងដែនការទូតចេញថ្វាយ និងជូនដល់ឥស្សរជនជាន់ខ្ពស់ និងមន្ត្រីការទូតខ្មែរទៅតាមលំដាប់នៃឋានន្តរសក្តិ និងមុខតំណែង ព្រមទាំងសហព័ទ្ធ និងកូនដែលនៅក្នុងបន្ទុកនៅលីវហើយមានអាយុក្រោម ១៨ ឆ្នាំ ដូចខាងក្រោម ៖

១- ព្រះមហាវីរក្សត្រ ព្រះវររាជមាតា ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ឬសម្តេចព្រះរាជអគ្គមហេសី ។

២- ព្រះរាជបុត្រា ព្រះរាជបុត្រី ព្រមទាំងព្រះរាជវង្សានុវង្ស ដែលបញ្ជាក់ដោយក្រសួងព្រះបរមរាជវាំង ។

៣- ប្រធាន អនុប្រធាន និងសមាជិកព្រឹទ្ធសភា ប្រធាន អនុប្រធាន និងសមាជិករដ្ឋសភា ។

៤- ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

៥- នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ព្រមទាំងរដ្ឋលេខាធិការ ( ដែលជាប្រធានស្ថាប័នរបស់រាជរដ្ឋាភិបាល ) ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងអគ្គលេខាធិការរាជរដ្ឋាភិបាល ។

៦- ប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

៧- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងអគ្គស្នងការនគរបាលជាតិ ។

៨- ឧត្តមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ និង ឥស្សរជនដែលមានងារជាសម្តេច ។

៩- អតីតប្រធានព្រឹទ្ធសភា អតីតប្រធានរដ្ឋសភា អតីតនាយករដ្ឋមន្ត្រី អតីតឧបនាយករដ្ឋមន្ត្រី និងអតីតរដ្ឋមន្ត្រីក្រសួងការបរទេស ។

១០-នាយកខុទ្ទកាល័យព្រះមហាក្សត្រ នាយកខុទ្ទកាល័យប្រធានព្រឹទ្ធសភា នាយកខុទ្ទកាល័យប្រធានរដ្ឋសភា នាយកខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលតែងតាំងដោយព្រះរាជក្រឹត្យ ។

១១- ប្រធានពិធីការរបស់ព្រះមហាក្សត្រ ប្រធានពិធីការរបស់ប្រធានព្រឹទ្ធសភា ប្រធានពិធីការរបស់ប្រធានរដ្ឋសភា និងប្រធានពិធីការរបស់នាយករដ្ឋមន្ត្រី ។

១២-មន្ត្រីការទូតចាប់ពីអនុព័ន្ធឡើងទៅ ដែលត្រូវទៅធ្វើការនៅស្ថានទូត និងកុងស៊ុលនៅបរទេស ។

**មាត្រា ៣.-**

លិខិតឆ្លងដែនការទូតចេញថ្វាយ និងជូនដល់មន្ត្រីរាជការ និងឥស្សរជនខ្មែរទៅតាមលំដាប់នៃឋានន្តរសក្តិ និងមុខតំណែងសម្រាប់បំពេញបេសកកម្មដូចខាងក្រោម ៖

១- ប្រធាន និងអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២- សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

៣- រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងស្ថាប័ននានា ។

៤- ប្រធានអាជ្ញាធរជាតិ ប្រធានគណៈកម្មាធិការជាតិ និងប្រធានស្ថាប័នថ្នាក់ជាតិនានា ដែលតែងតាំងដោយព្រះរាជក្រឹត្យ ។

៥- ប្រធាន និងអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ប្រធាន និងអនុប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

៦- អគ្គលេខាធិការព្រឹទ្ធសភា អគ្គលេខាធិការរដ្ឋសភា អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការក្រសួងនានា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ។

៧- ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ។

៨- នាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ដែលតែងតាំងដោយព្រះរាជក្រឹត្យ ។

៩- ទីប្រឹក្សាថ្នាក់ដឹកនាំ /ឥស្សរជន និងមន្ត្រីកាន់តំណែងនានា ដែលមានឋានៈស្មើរដ្ឋលេខាធិការឡើងទៅ ។

១០-មន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈដែលមានតំណែងជាអគ្គនាយក ឬអគ្គាធិការដែលតែងតាំងដោយព្រះរាជក្រឹត្យ និងប្រធាននាយកដ្ឋាននៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (ស្របតាមការអនុវត្តន៍អន្តរជាតិ) ។

១១-មន្ត្រីផ្នែកយោធានិងនគរបាលដែលមានតំណែងជា អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួងការពារជាតិ អគ្គមេបញ្ជាការរង នាយសេនាធិការចម្រុះ នាយរងសេនាធិការចម្រុះ មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងទ័ពជើងអាកាស មេបញ្ជាការកងទ័ពជើងទឹក មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអគ្គស្នងការរងនគរបាលជាតិ ។

១២- អភិបាលរាជធានី និងខេត្ត ។

សហព័ទ្ធព្រមទាំងកូននៅក្នុងបន្ទុករបស់ឥស្សរជននិងមន្ត្រីរាជការខាងលើពុំត្រូវផ្តល់លិខិតឆ្លងដែនការទូតឡើយ ។

**មាត្រា ៤.-**

លិខិតឆ្លងដែនការទូតចេញថ្វាយ និងប្រគេនសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ ទាំងពីរគណៈ និងមន្ត្រីសង្ឃដែលមានងារជាសម្តេច ។

**មាត្រា ៥.-**

សុពលភាពនៃលិខិតឆ្លងដែនការទូតមានរយៈពេលដំបូង ០៣ ( បី ) ឆ្នាំ ហើយអាចបន្តសម្រាប់រយៈពេល ០៣ ( បី ) ឆ្នាំម្តង ក្នុងករណីដែលអ្នកកាន់លិខិតឆ្លងដែននេះនៅមានឋានៈ ឬមុខតំណែងដូចមានចែងក្នុងមាត្រា ២ មាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យនេះ ។ មន្ត្រីការទូតដែលចប់អាណត្តិបេសកកម្ម មន្ត្រីអស់ឋានៈ ឬមុខតំណែង មន្ត្រីចូលនិវត្តន៍ មន្ត្រីដែលមានពិរុទ្ធដែលត្រូវបានព្យួរក្របខ័ណ្ឌ និងមន្ត្រីដែលឈប់សម្រាកយូរ ដោយគ្មានបៀវត្សចាប់ពី ០៦ ( ប្រាំមួយ ) ខែឡើងទៅ នឹងពុំមានសិទ្ធិប្រើប្រាស់លិខិតឆ្លងដែនការទូតទៀតទេ ។

## ជំពូកទី ៣

## អំពីលិខិតឆ្លងដែនផ្លូវការ

**មាត្រា ៦.-**

១- លិខិតឆ្លងដែនផ្លូវការផ្តល់ជូនមន្ត្រីរាជការខ្មែរ សម្រាប់តែទៅបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេស ប៉ុណ្ណោះ ៖

ក- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ខ- ទីប្រឹក្សា ឬជំនួយការមានឋានៈស្មើប្រធាននាយកដ្ឋាន ដល់ អនុរដ្ឋលេខាធិការ ។

គ- អនុប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញារងសាលាឧទ្ធរណ៍ ចៅក្រម ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង ។

ឃ- អនុប្រធានអាជ្ញាធរជាតិ អនុប្រធានគណៈកម្មាធិការជាតិ អនុប្រធានក្រុមប្រឹក្សាជាតិ និងអនុប្រធានស្ថាប័នថ្នាក់ជាតិនានា ។

ង- ប្រធានសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរបស់រដ្ឋ ។

ច- មន្ត្រីដែលមានមុខតំណែងចាប់ពីអនុប្រធានការិយាល័យឡើងទៅ ។

ឆ- មន្ត្រីយោធា និងនគរបាលចាប់ពីវរសេនីយ៍ត្រីឡើងទៅ ។

ជ- បុគ្គលិកបម្រើសេវាស្ថានបេសកកម្មការទូត និងកុងស៊ុលនៅក្រៅប្រទេស ។

ឈ- អង្គរក្សអមដំណើរគណៈប្រតិភូថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ។

២- លិខិតឆ្លងដែនផ្លូវការប្រគេនព្រះសង្ឃទាំងពីរគណៈចាប់ពីអនុគណឡើងទៅ ។

**មាត្រា ៧.-**

មន្ត្រីរាជការ ដែលមានមុខតំណែងក្រោមអនុប្រធានការិយាល័យ មន្ត្រីយោធា និងមន្ត្រីនគរបាលដែលមានឋានន្តរសក្តិក្រោមវរសេនីយ៍ត្រីត្រូវកាន់លិខិតឆ្លងដែនផ្លូវការនៅពេលបំពេញបេសកកម្មនៅបរទេស ។ ដោយឡែកបើទៅចូលរួមវគ្គសិក្សា ឬសិក្ខាសាលា មន្ត្រីទាំងនោះត្រូវកាន់លិខិតឆ្លងដែនធម្មតាដោយមិនបង់តម្លៃលិខិតឆ្លងដែន ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនឹងធ្វើកំណត់ទូតទៅស្ថានទូតពាក់ព័ន្ធដើម្បីសុំទិដ្ឋាការដោយពុំចាំបាច់បង់តម្លៃទិដ្ឋាការ ។

**មាត្រា ៨.-**

សុពលភាពនៃលិខិតឆ្លងដែនផ្លូវការមានរយៈពេលដំបូង ០៣ ( បី ) ឆ្នាំ ហើយអាចបន្តរយៈពេល ០៣ ( បី) ឆ្នាំម្តង ។

## ជំពូកទី ៤

## សមត្ថកិច្ចផ្តល់ និងដកហូតលិខិតឆ្លងដែន

**មាត្រា ៩.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចផ្តល់លិខិតឆ្លងដែនការទូត និងផ្លូវការ ស្របតាមអនុក្រឹត្យនេះ ។

ការស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការត្រូវមានលិខិតស្នើសុំមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយបញ្ជាក់នូវកម្មវត្ថុនៃបេសកកម្ម រយៈពេល ថ្ងៃ ខែ និងប្រទេសដែលត្រូវទៅបំពេញបេសកកម្ម ។

លិខិតឆ្លងដែនការទូត និងផ្លូវការទាំងឡាយណាដែលពុំស្របទៅនឹងមាត្រា ២ មាត្រា៣ មាត្រា៤ និងមាត្រា៦ នៃអនុក្រឹត្យនេះនឹងលែងមានសុពលភាពប្រើប្រាស់ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដកហូត ឬបដិសេធរាល់លិខិតឆ្លងដែនការទូត និងផ្លូវការ ទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ។

រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានឆន្ទានុសិទ្ធិក្នុងការផ្តល់លិខិតឆ្លងដែនការទូត និងផ្លូវការដល់តស្សរជនណាម្នាក់ ក្នុងករណីចាំបាច់ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូតនិងផ្លូវការ និងអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ និងបទប្បញ្ញត្តិ

ទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យ នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**បម្លងជូន**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៨-២២១ ប្រ.ក

# ប្រកាស
## ស្តីពី
## អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ធ៧-០០-០៤ ប្រក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ
- បានឃើញប្រកាសលេខ ធ៧-០០-០៥ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ
- បានឃើញប្រកាសលេខ ធ៧-០០-០៦ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ២០០៨

# ស ម្រេ ច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងពង្រឹងអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅហៅថា "គ្រឹះស្ថាន" ដោយរៀបចំឱ្យមានរចនាសម្ព័ន្ធគណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ រួមមានក្រុមប្រឹក្សាភិបាលឯករាជ្យនិងសកម្ម គណៈប្រតិបត្តិនិងគណៈកម្មការជំនាញ ដែលចាំបាច់ប្រកបដោយគុណវុឌ្ឍិ សមត្ថភាព សុចរិតភាព ដើម្បីដឹកនាំ គ្រប់គ្រងគ្រឹះស្ថានឱ្យមានប្រសិទ្ធភាព ។

**ប្រការ ២.-**

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចតទៅ :

- ក្រុមប្រឹក្សាភិបាល ជាគណៈគ្រប់គ្រងដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យ លើការគ្រប់គ្រង និង ស្ថានភាពរបស់គ្រឹះស្ថាន ក្នុងនាមភាគទុនិក ដូចជាក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ដែលគ្រប់គ្រងដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឬក្រុមប្រឹក្សាត្រួតពិនិត្យដែលមានភារកិច្ចសមមូលនៃក្រុមហ៊ុន ដែលមានទម្រង់គតិយុត្តិផ្សេងគ្នា ។
- គណៈប្រតិបត្តិ ជាក្រុមបុគ្គលដែលទទួលខុសត្រូវលើការគ្រប់គ្រងដោយប្រសិទ្ធភាពលើគ្រឹះស្ថាន ស្របតាមប្រការ ៦ នៃប្រកាស លេខ ធ៧-០០-០៤ ប្រក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ ប្រការ ៥ នៃប្រកាសលេខ ធ៧-០០-០៥ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពី ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ ឬ ប្រការ ៥ នៃប្រកាសលេខ ធ៧-០០-០៦ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។
- គណៈកម្មការសវនកម្ម ជាគណៈកម្មការជំនាញដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង ។ ក្រុមប្រឹក្សាភិបាល ត្រូវកំណត់អំពីសមាជិកភាព ភារៈកិច្ច នីតិវិធី

ប្រតិបត្តិ និងលក្ខខណ្ឌដែលក្នុងនោះសវនករ និងបុគ្គលដទៃទៀតរបស់គ្រឹះស្ថានត្រូវជាប់ពាក់ព័ន្ធក្នុងការងាររបស់ខ្លួន ។

- គណៈកម្មការគ្រប់គ្រងហានិភ័យ ជាគណៈកម្មការជំនាញ ដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង ។ ក្រុមប្រឹក្សាភិបាលត្រូវកំណត់អំពីសមាជិកភាពភារកិច្ច និងនីតិវិធីប្រតិបត្តិការរបស់គណៈកម្មការនេះ ។
- គណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ ជាគណៈកម្មការជំនាញ ដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង ។ ក្រុមប្រឹក្សាភិបាលត្រូវកំណត់អំពីសមាជិកភាពភារកិច្ច និងនីតិវិធីប្រតិបត្តិការរបស់គណៈកម្មការនេះ ។
- អ្នកគ្រប់គ្រងជាន់ខ្ពស់ ជាក្រុមប្រតិបត្តិគន្លឹះ ដែលមានភារកិច្ចមើលការខុសត្រូវលើការគ្រប់គ្រងប្រចាំថ្ងៃរបស់គ្រឹះស្ថាន ។

## ជំពូក ២
## ក្រុមប្រឹក្សាភិបាលឯករាជ្យ សកម្ម និងមានគុណវុឌ្ឍិ

**ប្រការ ៣.-**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវ :

- ឆ្លងកាត់ដំណើរការលក្ខខណ្ឌវិនិច្ឆ័យដ៏ត្រឹមត្រូវនិងសមស្របមួយដោយធនាគារជាតិនៃកម្ពុជា ដែលជាផ្នែកមួយនៃការផ្តល់អាជ្ញាប័ណ្ណ
- យល់ពីតួនាទីរបស់ខ្លួន រួមទាំងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន
- បើចាំបាច់ត្រូវទទួលការបណ្តុះបណ្តាល ដើម្បីរក្សាបានជំនាញរួមគ្នា
- យល់ពីភារកិច្ចរបស់ខ្លួនចំពោះភាគទុនិក ចំពោះគ្រឹះស្ថាន និងចំពោះអ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធ
- យល់ដឹងអំពីបរិស្ថានច្បាប់និងបទប្បញ្ញត្តិទាំងមូល ដើម្បីយល់ច្បាស់អំពីបញ្ហាដែលអាចកើតមានឡើង
- តាមដានស្ថានភាពទីផ្សារបច្ចុប្បន្ន និងយល់ដឹងអំពីបរិស្ថានប្រកួតប្រជែងនៃអាជីវកម្មរបស់គ្រឹះស្ថាន
- មានពេលវេលា និងថាមពលដែលអាចបំពេញការងារប្រកបដោយប្រសិទ្ធភាព ។

**ប្រការ ៤.-**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវសកម្មការងារ ។ យ៉ាងហោចណាស់ សមាជិកក្រុមប្រឹក្សាភិបាលត្រូវ :

- អនុម័តយុទ្ធសាស្ត្រ គោលនយោបាយហានិភ័យ និងនីតិវិធីគ្រប់គ្រងហានិភ័យទាំងនោះ
- រៀបចំរចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីឱ្យការពិភាក្សាមានប្រសិទ្ធភាព
- ជ្រើសរើស ត្រួតពិនិត្យ ផ្លាស់ប្តូរនាយកប្រតិបត្តិសំខាន់ៗ
- សាកសួរអ្នកគ្រប់គ្រងជាន់ខ្ពស់
- រៀបចំប្រព័ន្ធរាយការណ៍មួយដែលអាចជួយឱ្យការអនុវត្តកាតព្វកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលដែលមានលក្ខណៈយល់ដឹងបាន និងទាន់ពេល
- ជួបជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់ និងសវនករផ្ទៃក្នុងឱ្យបានទៀងទាត់
- វាយតម្លៃការប្រតិបត្តិរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់ឱ្យបានទៀងទាត់
- វាយតម្លៃគោលនយោបាយរបស់គ្រឹះស្ថានឱ្យបានទៀងទាត់ទៅលើការអនុវត្ត និងបញ្ហាជាសក្តានុពលដែលអាចសំគាល់បាន
- អនុវត្តនូវការវិនិច្ឆ័យសម្រាប់ពេលអនាគត ដើម្បីសំគាល់នូវបញ្ហាជាសក្តានុពលដែលគ្រឹះស្ថានត្រូវប្រឈម និងធានាថាសកម្មភាពកែតម្រូវសមស្របត្រូវបានអនុវត្តជាបន្ទាន់បើចាំបាច់

សមាជិកក្រុមប្រឹក្សាភិបាលនឹងត្រូវប្រជុំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ ។ សមាជិកនោះត្រូវបានដកចេញពីតំណែង ក្នុងករណីបុគ្គលនោះមិនបានចូលរួមអង្គប្រជុំក្រុមប្រឹក្សាភិបាលបីដង ជាបន្តបន្ទាប់ដោយគ្មានមូលហេតុត្រឹមត្រូវ ។

ក្រុមប្រឹក្សាភិបាល ត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជាជាបន្ទាន់រាល់ការផ្លាស់ប្តូរកម្មសិទ្ធិភាគហ៊ុននិង/ឬសិទ្ធិបោះឆ្នោតនៅក្នុងគ្រឹះស្ថាន។ កាតព្វកិច្ចជូនដំណឹងនេះមិនត្រូវធ្វើឡើងចំពោះតែការផ្លាស់ប្តូរការកាន់កាប់ដើមទុនឈានដល់ ៥% ឬ ២០% ឬនៃសិទ្ធិបោះឆ្នោត ប៉ុន្តែការជូនដំណឹងក៏ត្រូវធ្វើឡើងចំពោះការផ្លាស់ប្តូរដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់គ្រឹះស្ថាន តាមរយៈការកាន់កាប់សមាមាត្រភាគហ៊ុនឬនៃសិទ្ធិបោះឆ្នោត ។ ការជូនដំណឹងនេះជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ដោយមិនគិតដល់កាតព្វកិច្ចដែលតម្រូវដោយបទប្បញ្ញត្តិផ្សេងទៀតពាក់ព័ន្ធទៅនឹងភាគហ៊ុនថ្មី ឬភាគហ៊ុនដែលបានផ្ទេរ និង/ ឬនៃសិទ្ធិបោះឆ្នោត ។

**ប្រការ ៥.-**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវចេះវិនិច្ឆ័យឱ្យបានត្រឹមត្រូវ ហើយត្រូវ :

- ជៀសវាងទំនាស់ផលប្រយោជន៍
- មិនត្រូវចូលរួមធ្វើសេចក្តីសម្រេចនៅពេលមានទំនាស់ផលប្រយោជន៍
- ជំរុញសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថាន ។

**ប្រការ ៦.-**

១- សម្រាប់ធនាគារពាណិជ្ជ លើកលែងតែសាខាធនាគារបរទេស ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកឯករាជ្យយ៉ាងតិចពីររូប ។ សមាជិកឯករាជ្យត្រូវមានសមត្ថភាពវិនិច្ឆ័យដោយឯករាជ្យលើទស្សនៈនៃការគ្រប់គ្រង ផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ខាងក្រៅ ដែលមិនសមស្រប ។

២- សម្រាប់ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាល ត្រូវមានសមាជិកយ៉ាងតិច ៣រូប ដែលក្នុងនោះ មួយរូបត្រូវតែជាសមាជិកឯករាជ្យដូចបានចែងក្នុងចំណុច ១ ខាងលើ ។ ប្រសិនបើ គ្រឹះស្ថាននោះមានសមាជិកលើសពី៣រូប គ្រឹះស្ថានត្រូវធានាថាយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកត្រូវតែជាសមាជិកឯករាជ្យ ។

៣- សាខាធនាគារបរទេស ត្រូវអនុវត្តគោលនយោបាយអភិបាលកិច្ចត្រឹមត្រូវ និង នីតិវិធីអនុលោមតាមគោលការណ៍ដែលបានកំណត់នៅក្នុងប្រកាសនេះ ។ ភាពរឹងមាំនៃអភិបាលកិច្ចរបស់សាខាធនាគារបរទេសត្រូវសមស្របនឹងកម្រិតស្វ័យភាពនៃការគ្រប់គ្រង ដែលស្នាក់ការកណ្តាលបរទេសបានផ្តល់ឱ្យនាយកប្រតិបត្តិក្នុងស្រុក ។

**ប្រការ ៧.-**

គ្រឹះស្ថានត្រូវបង្កើតគណៈកម្មការសវនកម្ម និងគណៈកម្មការហានិភ័យ ហើយអាចបង្កើតគណៈកម្មការជំនាញផ្សេងទៀតតាមការចាំបាច់ ឬតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៨.-**

គណៈកម្មការសវនកម្មរបស់គ្រឹះស្ថាន ត្រូវដឹកនាំដោយសមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល ។ គណៈកម្មការនេះត្រូវមានយ៉ាងតិចបុគ្គលឯករាជ្យម្នាក់ដែលមាន ជំនាញឯកទេសផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ និងបុគ្គលឯករាជ្យម្នាក់ដែលមានជំនាញឯកទេសផ្នែកច្បាប់ និងធនាគារ ។

គណៈកម្មការសវនកម្ម ត្រូវទទួលខុសត្រូវជាអប្បបរមា ដោយ :

- ធានាថាព័ត៌មានដែលបានផ្តល់ជូនសាធារណជន និងធនាគារជាតិនៃកម្ពុជា ត្រឹមត្រូវនិងអាចជឿជាក់បាន
- វាយតម្លៃភាពសមស្របនៃវិធីសាស្ត្រគណនេយ្យ ដែលបានប្រើដើម្បីរៀបចំគណនីដោយឡែក និងគណនីរួមបញ្ចូលគ្នា ប្រសិនបើមាន
- វាយតម្លៃគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសវាយតម្លៃថាតើប្រព័ន្ធសម្រាប់វាស់វែង តាមដាន និងត្រួតពិនិត្យហានិភ័យមានសង្គតិភាព និងផ្តល់អនុសាសន៍លើសកម្មភាពអនុវត្តបន្តនៅពេលណាដែលសមស្រប ។

## ប្រការ ៩.-

គណៈកម្មការហានិភ័យរបស់គ្រឹះស្ថាន ត្រូវដឹកនាំដោយបុគ្គលដែលមានជំនាញខាងហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យ ។ បុគ្គលនោះត្រូវមានឯករាជ្យពីការងារគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃ ។

គណៈកម្មការហានិភ័យត្រូវទទួលខុសត្រូវជាអប្បបរមា លើការតាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ។

## ប្រការ ១០.-

ប្រសិនបើគ្រឹះស្ថានមានគណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ គណៈកម្មការនេះត្រូវដឹកនាំដោយសមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល ។

គណៈកម្មការនេះត្រូវមានយ៉ាងតិចបុគ្គលឯករាជ្យដែលមានជំនាញផ្នែកច្បាប់ និងធនាគារ ។

គណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ ត្រូវទទួលខុសត្រូវជាអប្បបរមា ដោយ :

- ធានាថាគោលនយោបាយផ្តល់តម្លៃការ មានសង្គតិភាពទៅនឹងគោលដៅរយៈពេលវែង និងតម្លៃរួម (Corporate Value) របស់គ្រឹះស្ថាន
- ផ្តល់អនុសាសន៍លើនីតិវិធីដើម្បីជ្រើសរើស និងផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាល
- ផ្តល់អនុសាសន៍ចំពោះបុគ្គលឯករាជ្យដែលនឹងក្លាយជាសមាជិកគណៈកម្មការ ដូចមានយោងក្នុងប្រកាសនេះ
- អនុម័តការតែងតាំងអ្នកគ្រប់គ្រងជាន់ខ្ពស់ ។

## ជំពូក ៣
## គោលដៅជាយុទ្ធសាស្ត្រ និងតម្លៃរបស់គ្រឹះស្ថាន

**ប្រការ ១១.-**

ក្រុមប្រឹក្សាភិបាលត្រូវកំណត់តម្លៃរួម និងធានាថា តម្លៃរួមទាំងនោះត្រូវបានផ្សព្វផ្សាយ យល់ដឹង និងទទួលយកទូទាំងគ្រឹះស្ថាន ។ តម្លៃទាំងនេះត្រូវគិតពីផលប្រយោជន៍របស់ភាគទុនិក និងអ្នកផ្ញើប្រាក់ផងដែរ ។

**ប្រការ ១២.-**

ក្រុមប្រឹក្សាភិបាលត្រូវធានាថា គោលនយោបាយនិងនីតិវិធី ត្រូវបានបង្កើតឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រតិបត្តិតាមទាំងស្រុង ជាពិសេសទាក់ទងទៅនឹងចំណុចដូចខាងក្រោម :

- ទំនាស់ផលប្រយោជន៍
- ការផ្តល់ឥណទានដល់បុគ្គលិកជាន់ខ្ពស់ និងនិយោជិត
- ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ និងបុគ្គលសម្ព័ន្ធ ។

**ប្រការ ១៣.-**

ទំនាស់ផលប្រយោជន៍ដែលមានសក្តានុពលត្រូវតែមានការយកចិត្តទុកដាក់ជាពិសេសពីក្រុមប្រឹក្សាភិបាល :

- នៅពេលដែលគ្រឹះស្ថានជាផ្នែកមួយនៃចង្កោមក្រុមហ៊ុន
- ទំនាស់ផលប្រយោជន៍ត្រូវតែទប់ស្កាត់ គ្រប់គ្រង និងបើកចំហ
- ត្រូវកំណត់របាំងព័ត៌មាន ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍
- ព័ត៌មានរបស់អតិថិជនត្រូវតែច្បាស់លាស់ និងត្រឹមត្រូវអំពីទំនាស់ផលប្រយោជន៍
- អ្នកត្រួតពិនិត្យត្រូវតែបានជូនដំណឹងយ៉ាងជិតដល់អំពីទំនាស់ផលប្រយោជន៍ដែលមានសក្តានុពល ។

## ជំពូក ៤
## ភាពច្បាស់លាស់ស្តីពីការទទួលខុសត្រូវ

### ប្រការ ១៤.-

ក្រុមប្រឹក្សាភិបាល ត្រូវកំណត់ការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ និងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់ ត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវបង្កើតវិធានច្បាស់លាស់ ដើម្បីផ្ទេរភារកិច្ចរបស់ខ្លួនទៅបុគ្គលិក។ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវបង្កើតផងដែរនូវកាតព្វកិច្ចរាយការណ៍ច្បាស់លាស់ ក្នុងគោលបំណងគាំទ្រដល់ការតាមដានការប្រតិបត្តិតាមវិធានដែលត្រូវបានបង្កើតឡើងខាងលើ ប្រកបដោយប្រសិទ្ធភាព។

អ្នកគ្រប់គ្រងជាន់ខ្ពស់ដែលជាផ្នែកមួយនៃគណៈប្រតិបត្តិ ដូចដែលបានកំណត់និយមន័យក្នុងប្រការ ២ នៃប្រកាសនេះ ត្រូវឆ្លងកាត់ដំណើរការលក្ខខណ្ឌវិនិច្ឆ័យដ៏ត្រឹមត្រូវនិងសមស្របមួយ ដោយធនាគារជាតិនៃកម្ពុជា មុននឹងទទួលភារកិច្ចជាអ្នកប្រតិបត្តិជាន់ខ្ពស់នៅក្នុងគ្រឹះស្ថាន ។

### ប្រការ ១៥.-

នៅក្នុងក្រុមសម្ព័ន្ធធនាគារ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុមសម្ព័ន្ធនិងនៅថ្នាក់ក្រុមហ៊ុននីមួយៗដែលជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់ក្រុមសាជីវកម្ម ។ ក្រុមប្រឹក្សាភិបាល របស់បុគ្គលសម្ព័ន្ធណាមួយ ត្រូវរក្សាឱ្យបានពេញលេញនូវការទទួលខុសត្រូវលើអភិបាលកិច្ចរបស់ខ្លួន។ ដូចគ្នានេះដែរ ការផ្តល់សេវាសំខាន់ៗពីប្រភពខាងក្រៅគ្រឹះស្ថាន មិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការពិនិត្យមើលសកម្មភាព និងការគ្រប់គ្រងហានិភ័យបានឡើយ។

### ប្រការ ១៦.-

ក្រុមប្រឹក្សាភិបាលត្រូវធានាថា មានការត្រួតពិនិត្យសមស្រប ត្រឹមត្រូវពីអ្នកគ្រប់គ្រងជាន់ខ្ពស់ ស្របតាមគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល។ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវមានជំនាញជាចាំបាច់។

អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវលើសេចក្តីសម្រេច និងសកម្មភាពរបស់ខ្លួនចំពោះក្រុមប្រឹក្សាភិបាល។ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលយក និងអនុវត្តតាមទាំងស្រុងនូវគោលនយោបាយដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង និងត្រូវរាយការណ៍ឱ្យបានទៀងទាត់ទៅក្រុមប្រឹក្សាភិបាល

អំពីទម្រង់ហានិភ័យ លទ្ធផលនៃការអនុវត្ត បញ្ហាផ្សេងៗ វិវាទចម្បងរបស់គ្រឹះស្ថាន និងបញ្ហាចំពោះមុខ និងជាសក្តានុពលនៃបទប្បញ្ញត្តិ ។

## ជំពូក ៥

## ការលើកកំពស់គុណភាព និងប្រសិទ្ធភាពនៃសវនកម្ម

**ប្រការ ១៧.-**

ក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ ត្រូវប្រើប្រាស់ការងាររបស់សវនករ និងមុខងារត្រួតពិនិត្យផ្ទៃក្នុង ឱ្យមានប្រសិទ្ធភាព :

- អ្នកគ្រប់គ្រងត្រូវផ្សព្វផ្សាយឱ្យមានការទទួលស្គាល់ពីសារៈសំខាន់នៃការងាររបស់សវនករខាងក្នុង និងខាងក្រៅ ទូទាំងគ្រឹះស្ថាន
- លទ្ធផលរកឃើញរបស់សវនកម្មផ្ទៃក្នុងត្រូវតែប្រើប្រាស់សម្រាប់ សកម្មភាពកែតម្រូវដោយប្រសិទ្ធភាព គ្រប់កាលៈទេសៈដែលតម្រូវ
- ការអនុវត្តទាន់ពេលវេលានូវសកម្មភាពកែតម្រូវដែលចាំបាច់ និងប្រកបដោយប្រសិទ្ធភាពត្រូវតែពិចារណាយោងតាមភាពធ្ងន់ធ្ងរនៃការរកឃើញ និងហានិភ័យដែលនាំឱ្យមានការធ្លាក់ដុនដាបជាបន្តបន្ទាប់នៃទម្រង់ហានិភ័យរួម និងស្ថានភាពប្រតិបត្តិតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថាន។

## ជំពូក ៦

## គោលនយោបាយលាភការ

**ប្រការ ១៨.-**

តាមការចាំបាច់ ក្រុមប្រឹក្សាភិបាល និងគណៈកម្មការតែងតាំងនិងផ្តល់តម្លៃការ ត្រូវធានាថាការអនុវត្តនិងគោលនយោបាយលាភការមានសង្គតិភាពជាមួយនឹងវប្បធម៌សាជីវកម្ម (Corporate Culture) យុទ្ធសាស្ត្រនិងគោលដៅរយៈពេលវែង និងបរិយាកាសត្រួតពិនិត្យរបស់គ្រឹះស្ថាន។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់ ឬ អនុម័តលាភការដល់សមាជិកក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់។

តម្លៃការជូនទៅនាយកមិនប្រតិបត្តិ ត្រូវសមាមាត្រទៅនឹងការចូលរួមរបស់អ្នកទាំងនោះ

ប៉ុន្តែការផ្តល់តម្លៃការនោះ មិនទាក់ទងនឹងលទ្ធផលរយៈពេលខ្លីរបស់គ្រឹះស្ថានទេ ។

រង្វាន់លើកទឹកចិត្តចំពោះសមាជិកក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ ត្រូវមានគោលដៅបង្កើនតម្លៃរួម (Corporate Value) រយៈពេលវែង ។

## ជំពូក ៧

## តម្លាភាព

**ប្រការ ១៩.-**

គ្រឹះស្ថានត្រូវតែដឹកនាំគ្រប់គ្រងប្រកបដោយមានតម្លាភាព។ ការបើកចំហដល់សាធារណជនត្រូវតែសមាមាត្រទៅនឹងទំហំ សកម្មភាព ភាពស្មុគស្មាញ និងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន។ ការបើកចំហ យ៉ាងហោចណាស់ត្រូវមានដូចខាងក្រោម :

- រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថាន
- រចនាសម្ព័ន្ធភាគទុនិក
- រចនាសម្ព័ន្ធរបស់ក្រុមសាជីវកម្ម បើអាចធ្វើបានត្រូវឱ្យសមស្របទៅនឹងកម្មសិទ្ធិភាពភាគហ៊ុនដែលត្រូវបានកាន់កាប់
- រចនាសម្ព័ន្ធចាត់តាំង
- រង្វាន់លើកទឹកចិត្ត
- ក្រមប្រតិបត្តិ ឬ ក្រមសីលធម៌
- គោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍
- គោលនយោបាយឥណទាន និងកិរិតកំណត់ដែលត្រូវអនុវត្តចំពោះសម្ព័ន្ធញាតិនិងបុគ្គលសម្ព័ន្ធ

## ជំពូក ៨

## ការយល់ដឹងអំពីរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន

**ប្រការ ២០.-**

ក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ :

- ត្រូវយល់ដឹងអំពីរចនាសម្ព័ន្ធប្រតិបត្តិការរបស់គ្រឹះស្ថាន រួមទាំងនៅពេលដែលគ្រឹះស្ថានធ្វើប្រតិបត្តិការនៅក្នុងយុត្តាធិការ ឬ តាមរយៈរចនាសម្ព័ន្ធណាមួយដែលរារាំងដល់តម្លាភាព

- ត្រូវធានាថា អ្នកគ្រប់គ្រងជាន់ខ្ពស់អនុវត្តតាមគោលនយោបាយច្បាស់លាស់ចំពោះប្រតិបត្តិការដែលត្រូវបានធ្វើតាមរយៈរចនាសម្ព័ន្ធ ឬ យុត្តាធិការ ដែលគ្មានតម្លាភាព
- ត្រូវមានគោលនយោបាយសមស្របសម្រាប់ការអនុម័ត និងពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធ ហិរញ្ញវត្ថុ ឧបករណ៍ ឬ ផលិតផល ដែលមានភាពស្មុគស្មាញ
- ត្រូវធានាថា សវនកម្មផ្ទៃក្នុងមិនត្រូវទុកឱ្យរចនាសម្ព័ន្ធ ឬ សកម្មភាព ទាំងនេះស្ថិតនៅក្រៅការត្រួតពិនិត្យឡើងវិញជាប្រចាំរបស់ខ្លួនឡើយ
- ត្រូវធានាថាការផ្តល់សេវាពីខាងក្រៅ ចំពោះសកម្មភាពសំខាន់ៗ នៅតែស្ថិតនៅក្រោមការត្រួតពិនិត្យគ្រប់គ្រាន់ និងធានាថាហានិភ័យដែលផ្សារភ្ជាប់និងការផ្តល់សេវាពីខាងក្រៅនេះ ត្រូវបានសំគាល់ និងតាមដានពេញលេញ។

## ជំពូក ៩
## អន្តរប្បញ្ញត្តិ

**ប្រការ ២១.-**

១- បន្ទាប់ពីប្រកាសនេះចូលជាធរមាន ធនាគារពាណិជ្ជ និងធនាគារឯកទេសលើកលែងតែសាខាធនាគារបរទេស ត្រូវអនុវត្តឱ្យបានពេញលេញនូវបញ្ញត្តិ និងលក្ខខណ្ឌទាំងឡាយនៃអភិបាលកិច្ច ជាពិសេសប្រការ៦នៃប្រកាសនេះ ដោយមិនឱ្យលើសពីៈ

- ១២ខែ សម្រាប់គ្រឹះស្ថានដែលមានចំនួនបុគ្គលិកលើសពី ៣០០នាក់ ឬទ្រព្យសកម្មសរុបច្រើនជាង ៤០០ពាន់លានរៀល
- ១៨ខែ សម្រាប់គ្រឹះស្ថានដែលមានចំនួនបុគ្គលិកពី ១៥០នាក់ ដល់ ៣០០នាក់ ឬ ទ្រព្យសកម្មសរុបពី ២០០ពាន់លានរៀល ដល់៤០០ពាន់លានរៀល និង
- ២៤ខែ សម្រាប់គ្រប់គ្រឹះស្ថានដទៃទៀតដែលមានចំនួនបុគ្គលិកតិចជាង ១៥០នាក់ ឬទ្រព្យសកម្មសរុបតិចជាង ២០០ពាន់លានរៀល។

២- ក្នុងអំឡុងពេល៩ខែបន្ទាប់ពីប្រកាសនេះចូលជាធរមាន គ្រឹះស្ថានត្រូវផ្តល់ផែនការសកម្មភាពមកធនាគារជាតិនៃកម្ពុជា ដោយរៀបរាប់លំអិតពីសកម្មភាពដែលបានអនុវត្ត និងត្រូវអនុវត្តឱ្យពេញលេញតាមលក្ខខណ្ឌដែលបានកំណត់។ ផែនការសកម្មភាពនេះត្រូវរៀបរាប់ពីៈ

- លក្ខណៈសម្បត្តិដែលធនាគារត្រូវការ សម្រាប់បំពេញមុខតំណែងក្នុងអង្គការលេខដែលបានគ្រោងទុក

- ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ចំពោះសមាជិកក្រុមប្រឹក្សាឯករាជ្យ និងសមាជិកក្រុមប្រឹក្សាដទៃទៀត និង
- ការទទួលខុសត្រូវ ចំពោះសមាជិកក្រុមប្រឹក្សាដទៃទៀត ជាពិសេសជាមួយ គណៈកម្មការដែលត្រូវបង្កើតឡើង ។

៣- ផែនការសកម្មភាព អង្គការលេខដែលបានគ្រោងទុក និងការទទួលខុសត្រូវដែលបានរៀបរាប់ខាងលើឱ្យបានច្បាស់លាស់ត្រូវរាយការណ៍ទាន់ពេលវេលាមកធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២២.-**

ក្នុងអំឡុងពេល៩ខែបន្ទាប់ពីប្រកាសនេះចូលជាធរមាន សាខាធនាគារបរទេសត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជា ស្តីពីគោលនយោបាយនិងនិតិវិធីនៃអភិបាលកិច្ច ដោយត្រូវរៀបរាប់ពីៈ

- ស្វ័យភាពនៃសិទ្ធិសម្រេចដែលផ្តល់ដោយទីស្នាក់ការកណ្តាល
- គោលនយោបាយ និងនិតិវិធីនៃអភិបាលកិច្ច និងការគ្រប់គ្រងដោយទីស្នាក់ការកណ្តាលដែលសាខាត្រូវអនុវត្តតាម
- បណ្តាញនៃការរាយការណ៍របស់គណៈប្រតិបត្តិសាខា ទៅសមាជិកក្រុមប្រឹក្សាភិបាល និងការទទួលខុសត្រូវក្នុងគ្រឹះស្ថាន ដែលកំណត់ដោយទីស្នាក់ការកណ្តាល
- ការផ្តល់សិទ្ធិអំណាចដោយទីស្នាក់ការកណ្តាល ចំពោះគណៈប្រតិបត្តិសាខាក្នុងស្រុក និង
- និតិវិធី និងគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងសិទ្ធិអំណាចដែលតម្រូវដោយទីស្នាក់ការកណ្តាលដើម្បីឱ្យសាខាមានសិទ្ធិធ្វើប្រតិបត្តិការ ។

ច្បាប់ចម្លងនៃរាល់ឯកសារខាងលើ ត្រូវភ្ជាប់ជាមួយរបាយការណ៍ផ្តល់មកធនាគារជាតិនៃកម្ពុជា ។

ធនាគារជាតិនៃកម្ពុជា អាចទាមទារឱ្យធ្វើបច្ចុប្បន្នកម្មតាមព្រានរបាយការណ៍ទាំងនោះ សំដៅវាយតម្លៃ ភាពខ្លាំងនិងភាពខ្សោយ នៃការត្រួតពិនិត្យនិងអភិបាលកិច្ចរបស់សាខាធនាគារបរទេស ។

**ប្រការ ២៣.-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យបានពេញលេញមិនឱ្យលើសពី២៤ខែបន្ទាប់ពីប្រកាសនេះចូលជាធរមាន ។ គ្រឹះស្ថានត្រូវផ្តល់ផែនការសកម្មភាពមកធនាគារជាតិនៃកម្ពុជា ដោយរៀបរាប់លំអិតពីសកម្មភាពដែលបានអនុវត្ត និងត្រូវអនុវត្តឱ្យពេញលេញតាមលក្ខខណ្ឌដែលបានកំណត់ ។ ផែនការសកម្មភាពនេះត្រូវរៀបរាប់ពីៈ

- លក្ខណៈសម្បត្តិដែលធនាគារត្រូវការ សម្រាប់បំពេញមុខតំណែង ក្នុងអង្គការលេខដែលបានគ្រោងទុក
- ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ចំពោះសមាជិកក្រុមប្រឹក្សាឯករាជ្យ និងសមាជិកក្រុមប្រឹក្សាដទៃទៀត និង
- ការទទួលខុសត្រូវ ចំពោះសមាជិកក្រុមប្រឹក្សាដទៃទៀត ជាពិសេសជាមួយ គណៈកម្មការដែលត្រូវបង្កើតឡើង។

ក្នុងករណីចាំបាច់ គ្រឹះស្ថានត្រូវផ្តល់ផែនការសកម្មភាពខាងលើមកធនាគារជាតិនៃកម្ពុជាក្នុងអំឡុងពេល ៩ខែ។

## ជំពូក ១០

## អវសានប្បញ្ញត្តិ

**ប្រការ ២៤.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថាន នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ២៥.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៨

ទេសាភិបាល

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ២៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.08 - 211 Prokor

**Unofficial translation**

# PRAKAS ON GOVERNANCE IN BANKS AND FINANCIAL INSTITUTIONS

The Governor of the National Bank of Cambodia

With reference to the Constitution of the Kingdom of Cambodia;

With reference to the Royal Kram NS/RKM/0196/27 of January 26, 1996, promulgating the Law on the Organization and Functioning of the National Bank of Cambodia;

With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;

With reference to the Royal Kram NS/RKM/0605/019 of June 19, 2005, promulgating the Law on Commercial Enterprises;

With reference to the Royal Decree NS/RKT/0508/526 of May 13, 2008, on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia, equivalent to Senior Minister;

With reference to the Prakas B7-00-04 on the Licensing of Commercial Banks; dated January 10, 2000;

With reference to the Prakas B7-00-05 on the Licensing of Rural Credit Specialized Banks; dated January 11, 2000;

With reference to the Prakas B7-00-06 on the Licensing of Micro-Finance Institutions; dated January 11, 2000;

Pursuant to the recommendation made by National Bank of Cambodia management during the October 03, 2008, meeting.

Decides:

Chapter 1
General Regulations

*Article 1*
The purpose of this Prakas is to strengthen governance of Banks and Financial Institutions, hereafter called "Institutions" by organizing different levels of management such as an independent and active board, an Executive board, and specialized committees with the qualifications, capacity and integrity for effectively managing the institutions.

*Article 2*
For the purposes of implementing this regulation the following definitions shall apply.

"Decision-making body" or "Board": the collegiate body that is responsible for supervising the management and situation of the financial institution on behalf of the shareholders, i.e., the board of directors of public limited companies governed by the Law on Commercial Enterprises or the equivalent supervisory board of firms having a different legal form.

"Executive body": the persons who are responsible for the effective management of the financial institution, referred to in Article 6 of the Prakas B7-00-04 on the Licensing of Banks, Article 5h of the Prakas B7-00-05 on the Licensing of Rural Credit Specialized Banks or Article 5h of the Prakas B7-00-06 on the Licensing of microfinance Institutions.

"Audit committee": a specialized committee that may be set up by the decision-making body. The decision-making body shall determine its membership, tasks, operating procedures and the conditions in which the statutory auditors and any other person belonging to the institution shall be involved in its work.

"Risk committee": a specialized committee that may be set up by the decision-making body. The decision-making body shall determine its membership, tasks and operating procedures.

"Remuneration and nomination committee": a specialized committee that may be set up by the decision-making body. The decision-making body shall determine its membership, tasks and operating procedures.

"Senior management": a group of key executives overseeing day-to-day management of the institution.

Chapter 2
Qualified, Active and Independent Board

*Article 3*
Board members should be qualified. This means that they shall:

- Undergo the fit and proper testing process at the NBC which is part of the licensing processes;
- Understand their role, including the institution's risk profile;
- Be trained if necessary so as to maintain a collective expertise;
- Understand their duties to shareholders, to the institution, and to stakeholders;
- Understand the overall regulatory environment in order to be knowledgeable of regulatory issues that could arise.
- Follow up on current market conditions and be knowledgeable of the competitive environment of the institution's business.
- Have time and energy to be able to act efficiently.

*Article 4*

Board members should be active. They should at least:

- Approve the institution's strategy, the risk policy and management procedures;
- Structure themselves in a way to make discussions efficient;
- Select, monitor, replace key executives;
- Question senior management;
- Design a reporting system that enables them to perform their duties in a timely and knowledgeable manner;
- Meet regularly with senior management and internal audit;
- Regularly assess their practices;
- Periodically assess the institution's policies in light of performance and potential issues and problems that can be identified;
- Exercise forward-looking judgment in order to identify potential issues and problems facing the institution and ensure that adequate corrective actions be taken promptly where required.

A board member shall attend meetings at least two times in one year. A board member shall be dismissed when he/she does not attend three consecutive board meetings without an appropriate reason.

It is the Board's responsibility to immediately inform the National Bank of Cambodia of any foreseen or of any existing changes in ownership and/or in voting rights held in the banking institution. This reporting responsibility not only concerns any change leading to reach a 5% or a 20% threshold in capital holdings or in voting rights held but also any change that would have a direct or indirect impact in terms of effective control of the banking institution, either through percentage of shares held or voting rights detained. This reporting responsibility applies to the Board without any prejudice to other regulatory requirements related to new or transferred shares and/or voting rights.

*Article 5*

Board members should exercise sound judgment. They should:

- Avoid conflicts of interest;
- Decline from participating in decision-making when in such conflict;
- Promote the institution's safety and soundness.

*Article 6*

1 *For commercial banks, except foreign bank branches, the board shall include at least two independent members. Independent members are defined as being capable of exercising judgment independent of the views of management, political interests or inappropriate outside interests.*

2 *For specialized banks and Microfinance Institutions, the body acting as a board of directors shall at least be composed of 3 board members, among whom 1 should be independent under the definition provided in Article 6.1. Should such institutions have a board of directors composed of more than 3 members, they shall ensure that, a minimum, one third of its members are independent.*

3 *Foreign bank branches are required to adopt good governance policies and procedures aimed at complying with the principles set forth in this Prakas. The strength of local governance of a foreign bank branch shall be commensurate with the level of management autonomy granted by foreign headquarters to local executives.*

*Article 7*
Institutions shall establish an Audit Committee and Risk Committee and may establish a Specialized Committee as needed or as required by NBC.

*Article 8*
The Audit Committee of Institutions shall be chaired by an independent board member. It shall include at least an independent person with expertise in finance and accounting, and an independent person with expertise in legal issues and banking.

As a minimum, the Audit Committee shall be responsible for:

- ensuring that the information provided to the public and to NBC is clear, accurate and reliable;
- assessing the relevance of the accounting methods used to prepare the individual and consolidated accounts, if any;
- assessing the quality of internal control procedures, in particular whether the systems for measuring, monitoring and controlling risks are consistent, and recommending further action where appropriate.

*Article 9*
The Risk Committee of Institutions shall be chaired by a person with expertise in finance and risk management. That person shall be independent from day-to-day operations.

As a minimum, the Risk Committee shall be responsible for monitoring the implementation of risk management policies, as defined by the board.

*Article 10*
If an Institution has a Remuneration and Nomination Committee, the committee shall be chaired by an independent board member. It shall include at least one independent person with expertise in legal issues and banking.

As a minimum, the Remuneration and Nomination Committee shall be responsible for:

- ensuring that the remuneration policy is consistent with the long-term objectives and corporate values of the institution;
- recommending procedures to select and replace board members;
- recommending independent persons who will become committee members as referred to in this Prakas;
- approving the nomination of senior management.

## Chapter 3
## Strategic objectives and corporate values

*Article 11*
The board should define corporate values and make sure they are spread, understood and adhered to within the organization. These corporate values must take into account the interests of shareholders and depositors.

*Article 12*
The board should make sure that policies and procedures are established in writing and fully complied with, especially with regard to the following:

- Conflicts of interest;
- Lending to officers and employees;
- Transactions with related parties and affiliates.

*Article 13*
Potential conflicts of interest deserve special attention from the board.

- Special attention is required where the institution is part of a group;
- Conflicts should be prevented, managed and disclosed;
- Information barriers should be set to avoid conflicts of interest;
- Information about clients should be clear and fair about conflicts of interest;
- Supervisors should be closely informed of potential conflicts of interest.

## Chapter 4
## Clear Lines of Responsibility

*Article 14*
The board should define its own responsibilities and those of senior management consistently with applicable laws and regulations.

Senior management should establish clear rules to delegate its duties to the staff. Senior management should also establish clear reporting requirements aimed at supporting an effective surveillance of compliance with the established rules discussed above.

Senior management which is part of the Executive Body, as defined in article 2 of this Prakas, shall undergo a fit and proper testing process at NBC prior to taking on their executive responsibilities within the institution.

*Article 15*
In banking groups, senior management should design the management structure at the group level and also at the level of each company that is part of the corporate group structure. The board of any subsidiary must fully retain its own governance responsibilities. Similarly, out sourcing of key functions does not eliminate the institution's responsibilities in overseeing activities and managing risks.

*Article 16*
The board should ensure that there is appropriate oversight by senior management consistent with board policy. The senior management should have the necessary skills.

Senior management shall be accountable for its decisions and actions towards the Board. Senior management should fully adhere to policies established by the board and should, on a regular basis, report to the board on the institution's risk-profile, performance, issues, major litigation and actual or potential regulatory issue(s).

## Chapter 5
## Promotion of Quality and Efficiency of Audit

*Article 17*
The board and senior management should effectively use the work of auditors and internal control functions.

- Management should communicate acknowledgement of internal and external auditors' work importance throughout the institution;
- Findings of internal audits should result in effective corrective action where and when required;

- Timely implementation of required and effective corrective actions shall be considered in light of the findings' gravity and of the risk for further deterioration of the overall institution's risk profile and regulatory compliance condition.

## Chapter 6
## Compensation policies

*Article 18*

The board and, where relevant, the Remuneration and Nomination Committee, should ensure that compensation policies and practices are consistent with the institution's corporate culture, long-term objectives and strategy, and control environment.

The board should determine or approve compensation of board members and senior management.

Remuneration of non-executive directors should be proportionate to their involvement but not related to the short-term performance of the institution.

Incentives for board members and senior managers should aim at enhancing long-term corporate value.

## Chapter VII
## Transparency

*Article 19*

Financial institutions should be governed in a transparent manner. Disclosure to the public should be proportionate to the financial institution's size, activity, complexity and risk profile. Disclosure should include at least the following:

- Board structure and management structure of the institution,
- Basic ownership structure,
- Where applicable, corporate group structure and corresponding ownership shares held,
- Organization,
- Incentives,
- Code of conduct or ethical code,
- Policies as regards conflicts of interest,
- Lending policies and limits applying to related parties and affiliates.

## Chapter 8
## Understanding of Institution's Structure

*Article 20*

The board and senior management:

- should understand the institution's operational structure, including where the institution operates in jurisdictions or through structures that impede transparency;
- should ensure that senior management follows clear policies as regards operating through non-transparent structures or jurisdictions;
- appropriate policies should be in place for the approval and review of complex financials structures, instruments or products;

- should make sure that internal audit does not leave these structures or activities out of their regular reviews;
- should ensure that outsourced key activities remain under sufficient control and that the corresponding risks are adequately identified and monitored.

## *Chapter 9*
## *Transitional Provisions*

*Article 21*

*1. Starting from the publication of the present regulation, commercial banks and specialized banks, except foreign bank branches, shall fully comply with all provisions and requirements established on governance and, more specifically, with the ones set forth in article 6 of this Prakas no later than:*

- *12 months for institutions with a total headcount of higher than 300 or total assets higher than KHR 400 thousand million, at publication,*
- *18 months for institutions with a total headcount of more than 150 but less than 300 or total assets from KHR 200 thousand million to KHR 400 thousand million at publication, and*
- *24 months for institutions with a total headcount below 150 or total assets below KHR 200 thousand million at publication.*

*2. Within 9 months from publication of the present regulation, banking and financial institutions shall provide NBC with an action plan detailing the steps taken/ to be taken in order to fully comply with the requirements set forth. This action plan shall notably discuss:*

- *the profiles the bank is looking for to fill the positions with respect to its targeted organizational structure,*
- *a clear description of responsibilities for both independent and other board members, and*
- *intended responsibilities of independent board members especially with regard to the committees to be established.*

*3. Action plan and targeted organization and responsibilities discussed above shall be clearly discussed and reported in a timely fashion to NBC.*

*Article 22*

*Foreign bank branches shall report in writing within 9 months from the publication of the present regulation to NBC on their governance policies and procedures. They shall discuss:*

- *the decision-making autonomy granted by their headquarters*
- *the policies and procedures established on governance and control matters by the headquarters they have to comply with*
- *detail the reporting lines of branch executives to the board members and their responsibilities within the institution such as established in the headquarters*
- *discuss the delegations granted by the head office to local executive managers*
- *discuss the established internal control policies and procedures local risk management processes and authorities required from head office to engage the institution through transactions performed by the branch.*

*Underlying documentation above shall be addressed to NBC, through copies and with the report.*

*NBC might require a periodic update of such reporting in order to update its assessment of the strengths and weaknesses of foreign bank branches' governance and controls.*

*Article 23*

*For microfinance institutions, compliance should be achieved no later than 24 months from publication of this regulation. Institutions shall provide NBC with an action plan detailing the steps taken/ to be taken in order to fully comply with the requirements set forth. This action plan shall notably discuss:*

- *the profiles the bank is looking for to fill the positions with respect to its targeted organizational structure,*
- *a clear description of responsibilities for both, independent and other board members and*
- *intended responsibilities of independent board members especially with regards to the committees to be established.*

*Where necessary, an action plan should be sent to NBC within 9 months of publication.*

## *Chapter 10*
## Final Provisions

*Article 24*

The General Directorate, the General Secretariat, the General Inspection, the General Cashier and all Departments of the National Bank of Cambodia, and all financial institutions under NBC's supervisory authority shall strictly implement this Prakas.

*Article 25*

This Prakas shall have effect from the signing date.

Phnom Penh, November 25, 2008
The Governor
signed and sealed

cc:
- All members of the Board of Directors
- The parties concerned as stated in Article 24
- File
- CM "for info"
- Administration Department of CM
  "for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៨-២១២ ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប សម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/៩២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ធ៧-០០-០៤ ប្រក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ
- បានឃើញប្រកាសលេខ ធ៧-០០-០៥ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ
- បានឃើញប្រកាសលេខ ធ៧-០០-០៦ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមប្រកាសលេខ ធ៧-០៨-២១១ ប្រក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៨

# សម្រេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះកំណត់នូវតម្រូវការអប្បបរមាចំពោះបុគ្គលដែលមានមុខងារសំខាន់នៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ឬបុគ្គលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវទទួលរងការវាយតម្លៃថាមាន " លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប " ក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន ។

គោលបំណងនៃប្រកាសនេះរួមមាន៖

១- ការពារផលប្រយោជន៍អ្នកដាក់ប្រាក់បញ្ញើ និងបុគ្គលដែលពាក់ព័ន្ធដោយធានាថាគ្រឹះស្ថានត្រូវបានគ្រប់គ្រងនិងដឹកនាំយ៉ាងត្រឹមត្រូវនិងប្រុងប្រយ័ត្ន

២- ដាក់ចេញនូវក្របខ័ណ្ឌអប្បបរមាស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ដែលគ្រឹះស្ថានអាចយកទៅប្រើប្រាស់ដើម្បីកំណត់ចំពោះបុគ្គលដែលនឹងទទួលតំណែងសំខាន់ៗ

៣- ដោះស្រាយហានិភ័យដែលបណ្តាលមកពីការគ្រប់គ្រងមិនត្រឹមត្រូវយ៉ាងធ្ងន់ធ្ងររបស់គ្រឹះស្ថាន និងទប់ស្កាត់ការគំរាមកំហែងជាសក្តានុពលដល់ប្រព័ន្ធធនាគារទាំងមូល និងការពារផលប្រយោជន៍របស់អ្នកដាក់ប្រាក់បញ្ញើ ។

**ប្រការ ២.-**

គ្រឹះស្ថានទាំងអស់ ត្រូវមានគោលនយោបាយផ្ទៃក្នុងគ្រប់គ្រាន់ ដែលហ្មត់ចត់និងច្បាស់លាស់តាមស្តង់ដារ សម្រាប់ជ្រើសរើសនាយកប្រតិបត្តិ និងអ្នកគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថាន ទោះបីជាការទទួលខុសត្រូវសំខាន់ក្នុងការកំណត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវពឹងផ្អែកជាចម្បងលើភាគទុនិក ។ អាជ្ញាធរត្រួតពិនិត្យក៏ទទួលខុសត្រូវផងដែរក្នុងការវាយតម្លៃពីភាព ស្មោះត្រង់ សុចរិត កិត្តិនាម ចំណេះដឹង និងសមត្ថភាព របស់បុគ្គលសំខាន់ៗក្នុងពេលបច្ចុប្បន្ននិងអនាគតក្នុងលក្ខខណ្ឌនៃការដឹកនាំគ្រឹះស្ថានប្រកបដោយប្រសិទ្ធភាព ។

បុគ្គលទាំងនេះ ត្រូវអនុវត្តឱ្យពេញលេញស្របតាមប្រកាសលេខ ធ៧-០៨-២១១ ប្រក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៣.-**

ក្នុងការអនុវត្តនូវលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ធនាគារជាតិនៃកម្ពុជា កំណត់ផងដែរសម្រាប់បុគ្គលដែលមានតំណែងសំខាន់ៗនៅក្នុងគ្រឹះស្ថាន ត្រូវមានកម្រិតសមត្ថភាព និង

បទពិសោធន៍ សមស្របទៅនឹងការទទួលខុសត្រូវរបស់ខ្លួន ។ ការវាយតម្លៃសមត្ថភាពនិងបទពិសោធន៍ ដោយផ្អែកលើទំហំនិងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន ក៏ដូចជាទំហំនិងភាពស្មុគស្មាញនៃអាជីវកម្ម និង ភាពជឿនលឿនហួសហេតុនៃប្រតិបត្តិការ ។

## ជំពូក ២

## បុគ្គលសំខាន់ៗ ត្រូវឆ្លងកាត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របដោយធនាគារជាតិនៃកម្ពុជា

**ប្រការ ៤.-**

បុគ្គលសំខាន់ៗត្រូវឆ្លងកាត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ដោយធនាគារជាតិនៃកម្ពុជា រួមមាន:

១- ក្រុមប្រឹក្សាភិបាល

២- អ្នកគ្រប់គ្រងជាន់ខ្ពស់ ដូចមានចែងនៅក្នុងប្រការ២ នៃប្រកាសលេខ ធ៧-០៨-២១១ ប្រក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

៣- នាយកសាខាធនាគារបរទេស និង

៤- បុគ្គលដែលមានតួនាទីជំនួសដោយការកំណត់ ឬបុគ្គលដែលទទួលបានសិទ្ធិប្រទានពីបុគ្គលដូចមានចែងខាងលើ ។

**ប្រការ ៥.-**

ការឆ្លងកាត់លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប សម្រាប់បុគ្គលដែលមានចែងនៅក្នុងប្រការ៤ ត្រូវអនុវត្តគ្រប់កាលៈទេសៈនៃការស្នើសុំដូចខាងក្រោម:

១- ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រតិបត្តិការធនាគារនិងហិរញ្ញវត្ថុ នៅកម្ពុជា

២- ការដាក់ពាក្យសុំបើកបុត្រសម្ព័ន្ធរបស់ធនាគារបរទេស នៅកម្ពុជា

៣- ការដាក់ពាក្យសុំបើកសាខាធនាគារបរទេស នៅកម្ពុជា

៤- រាល់ការសម្រេចរបស់កិច្ចប្រជុំភាគទុនិក ឬក្រុមប្រឹក្សាភិបាលដែលបណ្តាលឱ្យមានការកើនឡើងចំនួនសមាជិកក្រុមប្រឹក្សាភិបាល

៥- រាល់ការសម្រេចរបស់ធនាគារបរទេសដែលបង្កើតបុត្រសម្ព័ន្ធនៅកម្ពុជា ដែលបណ្តាលឱ្យមានការកែប្រែ ឬផ្លាស់ប្តូរចំនួនសមាជិកក្រុមប្រឹក្សាភិបាល

៦- រាល់ការសម្រេចទាំងឡាយណាដែលនាំទៅដល់ការតែងតាំងបុគ្គលជំនួស ឬបុគ្គលដែលទទួលសិទ្ធិប្រទានដូចមានចែងក្នុងប្រការ៤ ចំនុច ១, ២ និង៣ និង

៧- រាល់ការផ្លាស់ប្តូរដែលកើតមានបន្ទាប់ពីការបញ្ឈប់ឬការលាឈប់របស់បុគ្គលទាំងនោះ ។

## ជំពូក ៣
## តម្រូវការព័ត៌មាន

**ប្រការ ៦.-**

នៅក្នុងដំណើរការដាក់ពាក្យសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានថ្មី គ្រឹះស្ថានត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជា នូវព័ត៌មានដែលទាក់ទងនឹងលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របនៃបុគ្គលសំខាន់ៗសម្រាប់ជាឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ និងផ្តល់បន្ថែមនូវរចនាសម្ព័ន្ធចាត់តាំងដែលមានបញ្ជាក់ពី មុខងារនិងការទទួលខុសត្រូវនៃបុគ្គលទាំងនោះ ។

**ប្រការ ៧.-**

ចំពោះគ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ រាល់ការផ្លាស់ប្តូរបុគ្គលសំខាន់ៗត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារជាតិនៃកម្ពុជាមិនឱ្យលើសពី៣០ថ្ងៃ បន្ទាប់ពីការលាលែង ការចូលនិវត្តន៍ ឬការបញ្ឈប់បុគ្គលសំខាន់ៗនោះ ។

ធនាគារជាតិនៃកម្ពុជា នឹងធ្វើការពិនិត្យឡើងវិញនូវលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប នៃបុគ្គលដែលត្រូវបានស្នើសម្រាប់តំណែងទំនេរ ឬ តំណែងទើបបង្កើតថ្មី មុនពេលសម្រេចតែងតាំង ។ ធនាគារជាតិនៃកម្ពុជា មិនអាចបញ្ជាក់អំពីការទទួលយល់ព្រមការតែងតាំងទាំងនោះបានទេ មុនពេលបានទទួលនិងសិក្សាឡើងវិញនូវព័ត៌មានដែលតម្រូវឱ្យមាន ។

ធនាគារជាតិនៃកម្ពុជា អាចនឹងសំភាសន៍ជាមួយបុគ្គលដែលបានស្នើ ដើម្បីឱ្យប្រាកដអំពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របនៃបុគ្គលក្នុងឋានៈដែលត្រូវបានផ្តល់ឱ្យ និងទម្រង់ហានិភ័យរបស់គ្រឹះស្ថានទាំងមូល ។

**ប្រការ ៨.-**

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងនូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទៅគ្រឹះស្ថានក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីបានទទួលឯកសារគ្រប់គ្រាន់និងអាចទទួលយកបាន ។

## ជំពូក ៤
## ការវាយតម្លៃ និងលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប

**ប្រការ ៩.-**

បុគ្គលសម្រាប់តំណែងសំខាន់ៗនឹងត្រូវបានវាយតម្លៃ ដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យច្រើនប្រភេទ ដើម្បីកំណត់ថាបុគ្គលទាំងនោះមានលក្ខខណ្ឌត្រឹមត្រូវនិងសមស្របគ្រប់គ្រាន់ ដើម្បីបំពេញនូវ

ការទទួលខុសត្រូវ ដូចខាងក្រោម៖

១- ភាពស្មោះត្រង់ ភាពសុចរិត កិត្តិនាម និងភាពត្រឹមត្រូវ

២- ការសិក្សា ចំណេះដឹង និងសមត្ថភាព

៣- ស្ថានភាពហិរញ្ញវត្ថុរឹងមាំ

**ប្រការ ១០.-**

ធនាគារជាតិនៃកម្ពុជា នឹងធ្វើការពិចារណាលើកត្តាសមស្របជាច្រើន ដើម្បីវាយតម្លៃពីភាពស្មោះត្រង់ ភាពសុចរិត កិត្តិនាម និងភាពត្រឹមត្រូវ យ៉ាងតិចបំផុតមានដូចខាងក្រោម៖

១- បុគ្គលដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម និងបទឧក្រិដ្ឋ ឬកំហុសខាងវិន័យ

២- បុគ្គលដែលមានកំហុសដោយសារការក្លែង ឬផ្តល់នូវភស្តុតាងក្លែងបន្លំ

៣- ចំពោះភាគទុនិកដែលមានឥទ្ធិពល ឬបុគ្គលដែលមានសិទ្ធិត្រួតពិនិត្យ ត្រូវបានទទួលទណ្ឌកម្មខាងវិន័យ ឬ ព្យួរការងារដោយអាជ្ញាធរត្រួតពិនិត្យ ឬគ្រឹះស្ថានវិជ្ជាជីវៈ ឬតុលាការជាសាធារណៈ ឬជាឯកជន

៤- បុគ្គលដែលមានតួនាទីទទួលខុសត្រូវ ឬ ជាម្ចាស់ក្រុមហ៊ុន ឬស្ថាប័នដែលធ្លាប់ត្រូវបានបដិសេធពេលចុះបញ្ជីពាណិជ្ជកម្ម ឬបញ្ឈប់អាជីវកម្ម ឬត្រូវបានដកហូតអាជ្ញាប័ណ្ណ

៥- បុគ្គលដែលត្រូវបញ្ឈប់ពីការងារ ឬបង្ខំឱ្យលាលែងពីតំណែងដោយសារតែពាក់ព័ន្ធលើបញ្ហាភាពសុចរិត ឬភាពស្មោះត្រង់

៦- បុគ្គលដែលត្រូវបានដកហូតពីតំណែងជានាយក ឬជាអ្នកគ្រប់គ្រងដោយសារតែបានប្រព្រឹត្តខុស

៧- បុគ្គលដែលគ្មានសីលធម៌និងសច្ចៈធម៌ ក្នុងការទំនាក់ទំនងជាមួយអតិថិជន ថ្នាក់ដឹកនាំ សវនករ និងអាជ្ញាធរផ្សេងទៀត

៨- បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងសកម្មភាពដូចជា ការសំអាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ការក្លែងបន្លំ ឬអំពើពុករលួយ ទោះបីជាការប្រព្រឹត្តនោះមិនឈានដល់ការផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងប្រទេសខ្លះក្តី។

៩- បុគ្គលដែលគ្មានការវិនិច្ឆ័យនិងការសម្រេចចិត្តដោយឯករាជ្យ ដើម្បីប្រតិបត្តិតួនាទីរបស់ខ្លួន និង

១០-បុគ្គលដែលមិនបានត្រៀមជាស្រេច និងមិនមានបំណងប្រតិបត្តិតាមកាតព្វកិច្ចបទប្បញ្ញត្តិ និងការអនុវត្តដ៏ល្អ សំដៅទ្រទ្រង់សុវត្ថិភាពនិងភាពរឹងមាំនៃប្រព័ន្ធធនាគារ។

**ប្រការ ១១.-**

បុគ្គលត្រូវមានការសិក្សា ចំណេះដឹង បទពិសោធន៍ និងសមត្ថភាពគ្រប់គ្រាន់ដើម្បីស្វែងយល់នូវតម្រូវការបច្ចេកទេសអាជីវកម្ម ហានិភ័យដែលពាក់ព័ន្ធ និងដំណើរការគ្រប់គ្រងទាំងឡាយដោយមានការទទួលខុសត្រូវ ដើម្បីអនុវត្តប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងភាពរឹងមាំដោយគិតដល់ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់ ។

ធនាគារជាតិនៃកម្ពុជា នឹងពិចារណារាល់កត្តាពាក់ព័ន្ធទាំងឡាយក្នុងការវាយតម្លៃកម្រិតយល់ដឹងនិងសមត្ថភាពវិជ្ជាជីវៈនៃបុគ្គល យ៉ាងតិចបំផុតមានដូចខាងក្រោម៖

១- បុគ្គលដែលមានប្រវត្តិសិក្សាសមស្រប នាំឱ្យមានការយល់ដឹងត្រឹមត្រូវនិងគ្រប់គ្រាន់អំពីអាជីវកម្ម និងហានិភ័យដែលពាក់ព័ន្ធ ។

២- បុគ្គលដែលបានបង្ហាញថាមានសមត្ថភាពក្នុងការអនុវត្តតួនាទីប្រកបដោយជោគជ័យ តាមរយៈគុណវុឌ្ឍិ បទពិសោធន៍ និងការប្រតិបត្តិមុខតំណែងពីមុនមក ។

៣- បុគ្គលដែលមានចំណេះដឹងផ្នែកអាជីវកម្ម និងការទទួលខុសត្រូវចំពោះមុខតំណែង ហើយការយល់ដឹងនេះមានភាពសមស្របទៅនឹងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន ព្រមទាំងទំហំភាពស្មុគ្រស្មាញនៃអាជីវកម្ម និង ភាពឿនលឿនហួសហេតុនៃប្រតិបត្តិការ ។

